សិទ្ធិទទួលព័ត៌មាន

ព័ត៌មាន

Info.

FOI

FREEDOM OF INFORMATION

# បើកចំហព័ត៌មានសាធារណៈ

# តើអ្វីជាសិទ្ធិទទួលព័ត៌មាន?

គឺជាសិទ្ធិរបស់មនុស្សគ្រប់រូបក្នុងការទទួលបាននូវព័ត៌មានពីស្ថាប័នសាធារណៈទាំងឡាយ ហើយសិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់ ។

## ឧទាហរណ៍:

- ប្រជាពលរដ្ឋម្នាក់ មានសិទ្ធិទទួលបានព័ត៌មានពីក្រុមប្រឹក្សាឃុំ ទាក់ទងនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ឃុំដែលគាត់រស់នៅ ។

- អ្នកកាសែតម្នាក់ មានសិទ្ធិទទួលបានព័ត៌មានពីមន្ត្រីសាធារណៈនៃក្រសួងណាមួយដែលទាក់ទងទៅនឹងការដេញថ្លៃ និងការចំណាយផ្សេងៗរបស់ក្រសួងនោះ ។



# តើអ្វីជាព័ត៌មានសាធារណៈ?

ព័ត៌មានសាធារណៈ គឺជាព័ត៌មានទាំងឡាយដែលប្រមូល ចងក្រង និងកាន់កាប់ដោយស្ថាប័នសាធារណៈហើយស្ថិតនៅក្រោមបញ្ញត្តិច្បាប់ ឬទាក់ទងនឹងកិច្ចការផ្លូវការទាំងឡាយរបស់ស្ថាប័នសាធារណៈ។ ព័ត៌មានសាធារណៈ អាចមានទម្រង់ជា សៀវភៅក្រដាសស្នាម លិខិត ឯកសារ រូបថតភាពយន្ត ខ្សែអាត់ មីក្រូហ្វិស មីក្រូហ្វិលសំឡេងអាត់ទុក ផែនទី និងគំនូរ ខ្សែវីដេអូសំឡេងរូបភាព ឬទិន្នន័យសំឡេង និងវីដេអូ។



# តើសិទ្ធិទទួលព័ត៌មាន ជួយកាត់បន្ថយអំពើពុករលួយដូចម្តេច?

សិទ្ធិទទួលព័ត៌មាន គឺជាឧបករណ៍ដ៏សំខាន់មួយ ដែលធានាការបើកចំហ និងតម្លាភាព សម្រាប់លើកស្ទួយ អភិបាលកិច្ចល្អ និងកាត់បន្ថយអំពើពុករលួយ ។



# ប្រជាពលរដ្ឋខ្មែរ
# សូមអំពាវនាវយ៉ាងទទូចឱ្យ
# រាជរដ្ឋាភិបាលកម្ពុជាអនុម័ត
# ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន
# នៅឆ្នាំ ២០០៨។

